ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៧៦ អយក.ហវ

**សូមគោរពជូន**
**ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើសន្ទានកម្មរវាងប្រព័ន្ធ EFMS ជាមួយប្រព័ន្ធ FMIS របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៣។

**យោង ៖** លិខិតលេខ២៤០៣ អយក.ហវ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ក្រសួងបានកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡាជំនាន់ទី៣ (EFMS V3) បញ្ចប់សព្វគ្រប់ លើមុខងារវិភាជន៍ថវិកា(BA) បញ្ជាទិញ(PO) គណនីត្រូវសង (AP) និងរបាយការណ៍ ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការជូនអង្គភាពថវិកាក្រោមឱវាទក្រសួងផងដែរ។ ក្នុងន័យនេះ ក្រសួងស្នើសុំការអនុញ្ញាតជាគោលការណ៍ពី **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដើម្បីធ្វើសន្ទានកម្មរវាងប្រព័ន្ធEFMS និងFMIS សម្រាប់ការអនុវត្តឆ្នាំ២០២៣ ក្នុងការបង្កលក្ខណៈងាយស្រួលក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធទាំងពីរ ដែលជាបច្ច័យយ៉ាងល្អសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងមានប្រសិទ្ធភាពខ្ពស់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពនិងអនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានសន្ទានកម្មរវាងប្រព័ន្ធទាំងពីរសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៣ តទៅ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ ៣ ៤ ៦ ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២៣

**ចម្លងជូនៈ**
-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
" ដើម្បីជ្រាបជាព័ត៌មាន "
-កាលប្បវត្តិ
-ឯកសារ .នាយកដ្ឋានហិរញ្ញវត្ថុ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**